**BBI0087**

សម្ភាសន៍ជាមួយឈ្មោះ វ៉ង់ សន ភេទប្រុស អាយុ៤៩ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ យាមក្មៀវចិន និងកូរ៉េ

មុខងារបច្ចុប្បន្នៈ ប៉ះកង់ម៉ូតូ និងធ្វើស្រែចម្ការ

ស្រុកកំណើតៈ ភូមិពន្លៃ ឃុំពន្លៃ ស្រុកព្រៃកប្បាស ខេត្តតាកែវ

សព្វថ្ងៃរស់នៅភូមិកណ្ដាល ឃុំអូររំដួល ស្រុកភ្នំព្រឹក្ស ខេត្តបាត់ដំបង

ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី

០០:៥១:២៧

២៨ ទំព័រ

ដានី ៖ ជំបូងខ្ញុំចង់ស្គាល់ឈ្មោះ ពូឈ្មោះអីដែរ?

សន ៖ ខ្ញុំ វ៉ង់ សន ត្រកូលខ្ញុំតាមអត្តភាពវិញដាក់អត់ទៀងដែរ មេចេះតែដាក់ ។

ដានី ៖ ប៉ុន្តែឈ្មោះឥលូវ រាល់ថ្ងៃ?

សន ៖ ឈ្មោះខ្ញុំ វ៉ង់ សន ។

ដានី ៖ អាយុប៉ុន្មានហើយសព្វថ្ងៃ?

សន ៖ ខ្ញុំអាយុ៤៨-៤៩ហ្នឹង ។

ដានី ៖ ស្រុកកំណើតកើតជានៅណាដែរ?

សន ៖ នៅតាកែវហ្នឹងតែម្ដង នៅព្រៃកប្បាស ឃុំពន្លៃ ។

ដានី ៖ នៅភូមិពន្លៃ ។

សន ៖ ពីដើមស្រុកព្រៃកប្បាស ។

ដានី ៖ តាកែវ សព្វថ្ងៃនៅភូមិអីគេដែរ?

សន ៖ សព្វថ្ងៃនៅភូមិកណ្ដាល ។

ដានី ៖ ឃុំ?

សន ៖ ឃុំអូររំដួល ។

ដានី ៖ ស្រុក?

សន ៖ ភ្នំព្រឹក្ស ។

ដានី ៖ ខេត្តបាត់ដំបង?

សន :   ខេត្តបាត់ដំបង ។

ដានី :   ប្រពន្ធពូឈ្មោះអីដែរ?

សន :   ឈុន រ៉េន ។

ដានី :   គាត់អាយុប៉ុន្មានដែរ?

សន :   គាត់បង់ខ្ញុំ១ឆ្នាំ ៥០ឆ្នាំ ។

ដានី :   គាត់អ្នកស្រុកកំណើតនៅណាដែរ?

សន :   នៅទន្លេនាម ។

ដានី :   បាទ?

សន :   ទន្លេនាម យើងកំពត តាកែវ ព្រំដែនកំពត-តាកែវ ។

ដានី :   ភូមិអីម៉ិញ?

សន :   ភូមិអន្លាយ អីម៉េចទេ ឃុំសំឡាញ ។

ដានី :   ឃុំអីទន្លេនាមហ្នឹង?

សន :   ទាល់តែសួរប្រពន្ធខ្ញុំ ខ្ញុំហៅប្រពន្ធខ្ញុំ ។

ដានី :   អត់អីទេ ។ ទន្លេនាម ស្រុកអីគេនៅហ្នឹង?

សន :   មិនដឹងស្រុកអី ប៉ុន្តែខេត្តមិនដឹងតាកែវ ឬកំពត តែព្រំប្រទល់ហ្នឹងហើយ ព្រំប្រទល់កំពត តាកែវហ្នឹង ។

ដានី :   ពូសព្វថ្ងៃមានកូនចៅប៉ុន្មាននាក់ដែរ?

សន :   កូនចៅ៣ ។

ដានី :   កូន៣នាក់?

សន :   បាទ!

ដានី :   ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

សន :   ស្រីមួយពៅគេ ប្រុស២ ។

ដានី :   សព្វថ្ងៃពូប្រកបមុខរបររកស៊ីធ្វើអីដែរ?

សន :   ប៉ះកង់ម៉ូតូ ទៅណាមិនរួចក្បែរៗ ។

ដានី :   អត់ធ្វើស្រែចម្ការហ្នឹងគេទេ?

សន :   ចម្ការខ្ញុំធ្វើដែរ ធ្វើរួមផ្សំថវិការខ្លះ ។

ដានី :   ធ្វើចម្ការច្រើន?

សន ៖ ដីខ្ញុំប្រហែល៣០រ៉ៃ តែខ្ញុំអត់មានធនធានធ្វើ យើងឲ្យគេជួយធ្វើ ដូចជួលគេអីចឹង លទ្ធភាពដែលខ្ញុំធ្វើបានខ្លះ ខ្ញុំធ្វើបានខ្លះ ។

ដានី ៖ ដាំអីគេ?

សន ៖ ដាំដំឡូង ។

ដានី ៖ ដាំដំឡូង មានដាំស្រូវអីទេ?

សន ៖ ស្រូវឆ្នាំទៅដាំ ឆ្នាំនេះអត់មានបានដាំទេ ដាំដំឡូង ។

ដានី ៖ កូនធំៗហើយ?

សន ៖ កូនឆ្នាំនេះដប់ឆ្នាំជាង ១៥-១៦ឆ្នាំមីបង ពល់ថ្ងៃរៀនទាំងអស់ ។

ដានី ៖ បានរៀនទាំងអស់?

សន ៖ បាទ!

ដានី ៖ រៀននៅសាលា?

សន ៖ សាលាយើង នេះអូររលួស ។

ដានី ៖ ឪពុកពូគាត់ឈ្មោះអីដែរ?

សន ៖ ឪពុកខ្ញុំឈ្មោះ សុទ តែគាត់ខូចបាត់ហើយ ។

ដានី ៖ ឈ្មោះ សុទ អី?

សន ៖ បាទ!

ដានី ៖ គាត់ស្លាប់ឆ្នាំណា?

សន ៖ ស្លាប់កាលគេធ្វើមេភូមិបោះជំរុំ កៅប៉ុន្មាន ធ្វើមាតុភូមិនិវត្តន៍ទៅ កាលចេញពីតាមជំរុំទៅ ។

ដានី ៖ ៨២-៨៣?

សន ៖ កៅប៉ុន្មាន?

ដានី ៖ ម្ដាយ?

សន ៖ ម្ដាយខ្ញុំគាត់ខូចតាំងពីសម័យបីឆ្នាំ?

ដានី ៖ ឈ្មោះអីគេ?

សន ៖ សាំង ។

ដានី ៖ ស្លាប់សម័យ៣ឆ្នាំ ស្លាប់ដោយសារមូលហេតុអីគេ?

សន ៖ គាត់ឈឺ កង្វះខាតពេក ។

ដានី ៖ មានបងប្អូនទាំងអស់ប៉ុន្មាននាក់?

សន ៖ បងប្អូនបង្កើតនៅសល់តែ៣នាក់ ខូចអស់១ ។

ដានី ៖ ៤នាក់ ស្លាប់១នាក់?

សន ៖ នៅសល់តែ៣ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សន ៖ ស្រី៣ ប្រុសខ្ញុំពៅគេ ។

ដានី ៖ ស្រីទាំង៣ ប្រុស១ កូនពៅអីចឹង?

សន ៖ បាទ!

ដានី ៖ កាលពីក្មេងៗបានរៀនសូត្រអីដែរ?

សន ៖ ថារៀន ដូចជាមិនបានរៀនដែរជំនាន់ហ្នឹង ។

ដានី ៖ អត់បានចូលសាលាទេ?

សន ៖ ទៅបានចូលដែរ ។

ដានី ៖ ចូលបានប៉ុន្មាន?

សន ៖ ២-៣ខែ កាលហ្នឹងខ្ញុំនៅស្ទើរៗដែរ កាលជំនាន់យើងសង្គ្រាមរដ្ឋប្រហារ ។

ដានី ៖ មិនបាន១ឆ្នាំផង?

សន ៖ អត់បានទេ តែមើលអក្សរបានដាច់ខ្លះ មិនដាច់ខ្លះអីចឹង ។

ដានី ៖ ដូចជាអានសៀវភៅបានទេ?

សន ៖ ខ្ញុំទៅរៀន គេចេះតែបំពាក់បំប៉នថែម រៀនធ្វើម៉ូតូចេះតែបណ្តុះបណ្តាលទៅ ចាប់បានខ្លះ ។

ដានី ៖ កាលជំនាន់រដ្ឋប្រហារឆ្នាំ៧០ហើយ ពូនៅណា?

សន ៖ ខ្ញុំនៅភូមិហ្នឹងតែម្តង ។

ដានី ៖ នៅជាមួយឪពុកម្តាយ?

សន ៖ បាទ!

ដានី ៖ នៅរហូតដល់ពេលណាទៅ?

សន ៖ នៅរហូតដល់៧៦-៧៧ បានគេខ្ញុំយកទៅការពារភ្លៀវនៅបាត់ដំបង ។

ដានី ៖ កាលបែកភ្នំពេញឆ្នាំ៧៥ ពេលចូល?

សន ៖ ខ្ញុំនៅភូមិនៅឡើយ ។

ដានី ៖ នៅភូមិកំណើតកាលហ្នឹងធ្វើអីគេ?

សន ៖ ធ្វើស្រែធម្មតា ។

ដានី : ពេលបែកភ្នំពេញ?

សន : បែកភ្នំពេញហើយ នៅភូមិ ។

ដានី : នៅជាមួយឪពុកម្ដាយ ឬនៅក្នុងកង?

សន : នៅជាមួយឪពុកម្ដាយ កាលហ្នឹងកងកុមារដូចគេរៀបជិតប៉ុន្មានខ្ញុំក្មេចដែរ ចាំអត់សូវបានទេ ព្រោះ...ច្រើនដងដូចជាវិល ។

ដានី : មាននៅកងកុមារដែរ?

សន : បាទ! ខ្ញុំនៅកងកុមារ គេរៀបការហ្នឹងយកពីសិល្បៈភូមិមកឲ្យនៅកងកុមារ ធម្មតាឲ្យរែកដី អីចឹង រោយដី ធ្វើដីហ្នឹងគេឯង ។

ដានី : នៅកងកុមារហ្នឹងនៅរែកដី ហើយកាលមុនពូនៅសិល្បៈភូមិ?

សន : សិល្បៈឃុំតែម្ដងពន្លៃ ដល់ក្រោយមក ។

ដានី : គេឲ្យធ្វើអីខ្លះសិល្បៈឃុំ?

សន : គេចេះតែបង្ហាត់បង្រៀនអីចឹង រាំមួយពីរ នៅបានតិចដែលទេកាលហ្នឹងនៅបានប៉ុន្មានខែ ២-៣ខែ ។

ដានី : ដល់ក្រោយមកយើងនៅក្នុងកងកុមារដូចថារែកដី ធ្វើអីទៀត?

សន : ធ្វើស្រែធ្វើអីចឹង លើកប្រឡាយជីកអីចឹង ។

ដានី : ហ្នឹងបែកពីឪពុកម្ដាយ?

សន : បែក ហ្នឹងបែកអស់ហើយ ។

ដានី : នៅបានរយៈពេលប៉ុន្មានបានគេផ្លាស់ពូ?

សន : កាលហ្នឹងបើមិនដើមឆ្នាំ៧៧ ៧៨ខ្ញុំមកនៅការពារបាត់ដំបង ការពារភ្លៀវបាត់ដំបងកន្លែង អ្នកតាចាស់ កាលហ្នឹងគេយកខ្ញុំពីតាកែវមក ។

ដានី : គេយកពីតាកែវមក?

សន : បាទ! យកមកនៅការពារនៅហ្នឹង ការពារភ្លៀវនៅហ្នឹង ។ ដើមឆ្នាំ៧៧ ៧៩វៀតណាម ចូលហើយកាលហ្នឹង ។

ដានី : ម៉េចបានគេយកពូមក?

សន : កាលហ្នឹងខ្ញុំអត់សូវដឹងដែរ ដែនការគេ គេឲ្យទៅណាទៅហ្នឹង ។

ដានី : គេយកពីកន្លែងកងកុមារមក?

សន :	យកពីកន្លែងហ្វឹកហាត់ដែលខ្ញុំហ្វឹកហាត់នៅភ្នំទេពហ្នឹង កាលហ្នឹងគេដាក់នៅកន្លែងតាកែវនេះ ដាក់តាកែវបានប៉ុន្មានខែឲ្យវើកណ្ដុរ គេមានផែនការយកខ្ញុំមកទៀតមក ។

ដានី :	ឆ្នាំ៧៧គេដកពួពីកងកុមារឲ្យនៅកន្លែងហ្វឹកហាត់?

សន :	បាទ! ហ្វឹកហាត់នៅកន្លែងភ្នំទេព ។

ដានី :	ភ្នំទេព?

សន :	ភ្នំទេពជិតអង្គរបុរី ។

ដានី :	ហ្វឹកហាត់ពីអី?

សន :	ហាត់ទាហានតែម្ដង តែខ្ញុំមិនដឹងអាយុប៉ុន្មាន កាលហ្នឹងខ្ញុំ១៣-១៤ ហ្វឹកហាត់ទាហានហ្នឹងតែម្ដង បច្ចេកទេសទាហាន ។

ដានី :	ភ្នំយាយទេព?

សន :	គេហៅភ្នំទេពៗ ។

ដានី :	ជិតតាកែវភ្នំហ្នឹង?

សន :	ខាងនេះតាកែវ ជាប់ភ្នំអង្គរបុរី ខាងជើងភ្នំអង្គរបុរី ។

ដានី :	កន្លែងហ្នឹងដូចថាកាលហ្នឹងគេហៅកុមារ ស្របា៉ល់ពួមកច្រើនទេ?

សន :	ច្រើនណាស់តាមឃុំគេ ជ្រើសតាមឃុំមកតែម្ដង តាមស្រុក មកនៅបាត់ដំបង ហាត់នៅហ្នឹងគេឲ្យដឹកជញ្ជូនគ្រាប់តាមបេអ៊ីជើងទឹក បេអ៊ីរបស់អាមេរិកដឹកគ្រាប់ពី១០៥ ពីអង្គខ្នុរចេញចូលៗ ដល់ក្រោយមកទៀតគេយកខ្ញុំមកការពារភ្លៀវ ។

ដានី :	ដល់ពេលហាត់រយៈពេលប៉ុន្មានបានគេដក?

សន :	ហាត់យូរដែរ ហាត់ហ្នឹងផង បញ្ជូនគ្រាប់ផង ជញ្ជូនគ្រាប់ទៅអមសំណារ ហើយខ្ញុំភ្លេចកង ហើយតូចៗដែរកាលហ្នឹងចាំមិនសូវបានទេ ភ្លេចកាលខ្ញុំបែកភូមិ... ។

ដានី :	គេមានប្រាប់ថាម៉េច បានគេបញ្ជូនពួមកខាងបាត់ដំបង?

សន :	បញ្ជូនមកគេអត់មានប្រាប់អីកាលហ្នឹង បញ្ជូនមកចង់ភ័យដែរកាលហ្នឹង ដល់មកដល់បែកគ្នាទៀត មកដល់មានមួយផ្នែកទៅធ្វើ...មួយផ្នែកទៅរោងចក្រកំពង់គល់ ស្ពរស ហើយខ្ញុំគេឲ្យការពារភ្លៀវកាន់អាវុធហ្នឹង ។

ដានី :	ការពារភ្លៀវ?

សន :	បាទ! ការពារភ្លៀវចិន នៅកាន់អាវុធនៅហ្នឹង ។

ដានី :	គេអត់មានប្រាប់ទេ កាលគេបញ្ជូនមក?

សន ៖ បាទ!

ដានី ៖ កាលគេបញ្ជូនពីភ្នំទេពហ្នឹងមកខាងបាត់ដំបង គេអត់មានប្រាប់ថាបញ្ជូនមក?

សន ៖ អត់មានប្រាប់អី ដល់មកដល់បាត់ដំបងបានគេមានផែនការ ។

ដានី ៖ គ្នាប៉ុន្មាននាក់មក?

សន ៖ មកច្រើនដែរមួយរទេះភ្លើងមួយខ្សែ រទេះភ្លើងដឹកគោអាទ្រុងនេះ ។

ដានី ៖ ចេញពីត្រង់ណា?

សន ៖ ចេញពីតាកែវមកតែម្តង ។

ដានី ៖ ចេញពីតាកែវមក?

សន ៖ បាទ! ចេញពីតាកែវហូបបាយពោធិ៍សាត់ ប៉ុន្តែមកដល់បាត់ដំបងប្រហែលម៉ោងយប់១១-១២អីហ្នឹង ។

ដានី ៖ ១២យប់?

សន ៖ បាទ!

ដានី ៖ ចេញពីតាកែវស្ពានម៉ាណ?

សន ៖ ចេញព្រលប់ៗដែរហើយ រៀបមកគេចែកខោអាវ ចែកលុយ ចែកអី ។

ដានី ៖ គេមានអ្នកដឹកនាំ?

សន ៖ បាទ!

ដានី ៖ ពីណាគេអ្នកដឹកនាំ?

សន ៖ ខ្ញុំភ្លេចដែរ ខ្ញុំមិនសូវចាំកាលហ្នឹងនៅតូចៗ ។

ដានី ៖ អត់ចាំខែ?

សន ៖ អត់ ។ ខ្ញុំអត់ចាំដែរ ចាំតែឆ្នាំ ។

ដានី ៖ មកដល់ម៉ោង១២យប់ មកដល់បាត់ដំបង?

សន ៖ បាទ!

ដានី ៖ ដល់យើងចុះពីរទេះភ្លើងយើងទៅណាទៅ?

សន ៖ ចុះពីរទេះភ្លើងគេធ្វើបាយទទួល យើងហូបបាយ ។

ដានី ៖ ហូបបាយនៅណា?

សន ៖ ហូបបាយនៅបាត់ដំបង ។

ដានី ៖ ម្តុំណានៅបាត់ដំបង?

សន ៖ ខ្ញុំអត់ចាំដែលកាលហ្នឹង ផងឹតមកយប់តែម្តងខ្ញុំអត់សូវចាំ ។

ដានី ៖ ដល់ពេលហូបបាយហើយឲ្យ?

សន ៖ ហូបបាយហើយព្រលឹមឡើងបានប្រជុំជួរ គេដាក់ផែនការចែកតាមក្រុមៗអីចឹង ក្រុមខ្លះទៅពេទ្យ៣២ ក្រុមខ្លះទៅរោងចក្រកំពង់គល់ស្ករស ហើយក្រុមខ្ញុំនៅការពារភ្ញៀវ ។

ដានី ៖ នៅយាមការពារភ្ញៀវ?

សន ៖ បាទ! ការពារភ្ញៀវ ។

ដានី ៖ ក្រុមពូមានគ្នាប៉ុន្មាននាក់?

សន ៖ កាលហ្នឹង៤នាក់ អំពិល២នាក់ ហើយម្នាក់ទៀតបែកគ្នាទាំងអស់ ខ្ញុំ៤នាក់នេះស្លាក់នៅនេះ ខ្ញុំចាំនៅភូមិអំពិលម្នាក់ ប្រធានៗគាត់ទៅណាសព្វថ្ងៃអត់ដឹង ។

ដានី ៖ ក្រុមពូមានគ្នា៤នាក់អីចឹង?

សន ៖ បាទ! តែ៤នាក់ យកមកដាក់ចំរុះគ្នាតែម្តងកាលហ្នឹង វាមានកាលហ្នឹងមក៥៣ ៥៦ ៥៥ ។

ដានី ៖ ៥៣,៥៦ អីគេ?

សន ៖ កាលហ្នឹងសុទ្ធតែតំបន់ ចង់និយាយថាគេកាត់តំបន់ ដល់អីចឹងខ្ញុំគេហៅ៥៥ ។

ដានី ៖ ស្រុក៥៥ ឬតំបន់?

សន ៖ ស្រុក៥៥ ស្រុក៥៦, ៥៣ ហាប៉ុន្មានខ្លះទេខ្ញុំភ្លេចកាលហ្នឹង មកចំរុះមកតែម្តង ។

ដានី ៖ តែមកដល់យាមភ្ញៀវមានគ្នាតែ៤នាក់ទេ?

សន ៖ បាទ!

ដានី ៖ ពីណាខ្លះពូមានចាំទេ?

សន ៖ ខ្ញុំចាំតែ មិត្តគឿន នោះម្នាក់ ចំរុះតែម្តងកាលហ្នឹង ៥៦មាន ចំរុះដាក់ចូលគ្នាចំរុះតែម្តង ។

ដានី ៖ ពូមកពី៥៥ ស្រុកព្រៃកប្បាស៥៥?

សន ៖ បាទ! ស្រុកព្រៃកប្បាស ។

ដានី ៖ ចុះ គឿន?

សន ៖ គឿន នៅភូមិអំពិល ៥៥ដែរ ។

ដានី ៖ អំពិល៥៥ នៅយាមជាមួយគ្នា?

សន ៖ បាទ!

ដានី ៖ យាមនៅកន្លែងណាទៅ?

សន ៖ យាមនៅកន្លែង ៧មករា ចាស់កន្លែងស្ពានថ្មថ្មីហ្នឹង ។

ដានី ៖ ស្ពានថ្មថ្មីហ្នឹង?

សន ៖ បាទ! កន្លែងចំណតឡានក្រុង អាចំលាក់រូបសេះហ្នឹង កាលហ្នឹងនៅយាមហ្នឹង ហើយផ្ទះខ្ញុំនៅផ្សារបឹងឈូកហ្នឹងតែម្ដង ។

ដានី ៖ ផ្សារបឹងឈូក?

សន ៖ បាទ!

ដានី ៖ គេឲ្យយាមអីទៅ?

សន ៖ យាមភ្ញៀវចិនចំរុះកាលហ្នឹង កូរ៉េផង ចិនប៉េកាំងផង ។

ដានី ៖ ចិនហើយនិងកូរ៉េ?

សន ៖ បាទ!

ដានី ៖ ចិន និងកូរ៉េ គេធ្វើអីនៅហ្នឹង?

សន ៖ ខ្ញុំអត់ដឹងដែរកាលហ្នឹងគេឲ្យយាមចេះតែយាមទៅ វាមានខុសៗគ្នាទៀតកាលហ្នឹង វាមានខ្ញុំយាមខាងបរិវេណខាងក្រៅ តាមកន្លែងប៉ូរីយូមគេហ្នឹង ឬមកក្នុងចល័ត តាមស្ពានថ្មថ្មីហ្នឹង ។

ដានី ៖ ក្នុងហ្នឹងសុទ្ធតែចិន ហើយនិងកូរ៉េ?

សន ៖ បាទ!

ដានី ៖ ច្រើន?

សន ៖ ចិនច្រើនដែរ ផ្ទះមួយជំនៀរហ្នឹងទាំងអស់ ១រ៉ែកហ្នឹង(សើច) ។

ដានី ៖ ដែលនិយាយលេងជាមួយពួកគាត់ទេ?

សន ៖ អត់ដែរបានទៅជិតទេ ខ្ញុំយាមដឹងតែយាម គាត់អង្គុយខ្ញុំ ។

ដានី ៖ ចិនមកធ្វើអី មកធ្វើថ្នល់ដូចឥលូវ ឬធ្វើអី?

សន ៖ មិនដឹងធ្វើខាងអី ទូតៗ គេប្រាប់ថាទូតចិនៗ ។

ដានី ៖ នៅបាត់ដំបងហ្នឹងតែម្ដង?

សន ៖ នៅបាត់ដំបង ។

ដានី ៖ ឥលូវចិនអីមកធ្វើថ្នល់?

សន ៖ ហ្នឹងចិនមកធ្វើផ្លូវ នេះឃើញដាក់ស្តែង ។

ដានី ៖ តែជំនាន់នោះអត់ឃើញទេ?

សន ៖ ឃើញដាក់ស្តែងតែអត់បាន ។

ដានី ៖ អត់បានសួរនាំអី?

សន : អត់ហ៊ានសួរនាំ ។

ដានី : គេស្លៀកពាក់យ៉ាងម៉េចទៅចិន?

សន : ស្លៀកពាក់ធម្មតា ខោអាវខ្មៅៗ សៗធម្មតា ដូចយើងខោអាវធម្មតា ។

ដានី : ប្រធានពួលឈ្មោះអីទៅនៅកន្លែងយាមហ្នឹង?

សន : ឈ្មោះបង វុធ ស្គាល់តែឈ្មោះទេប៉ុន្តែរាល់ថ្ងៃឲ្យទៅរកក៏រកមិនឃើញ ។

ដានី : វុធ ហ្នឹងគាត់ធ្វើអីគេ?

សន : គាត់ក្តាប់នៅកន្លែងកងហ្នឹងតែម្តង ក្តាប់កងកន្លែងយាម ។

ដានី : ក្តាប់កងគ្នាច្រើនអីក្នុងកងយាមហ្នឹង?

សន : មួយកងតូច គ្នា៣០នាក់ មួយកងតូចមួយភូមិ៣០នាក់ ដូរគ្នា ផ្លាស់គ្នាយាមអីចឹង ។

ដានី : យាមប៉ុន្មានម៉ោងមួយថ្ងៃ?

សន : យាមយប់អីចឹង បើខ្ញុំយាមថ្ងៃពេលខ្ញុំឈប់យាមថ្ងៃ គេយាមយប់ ដូរគ្នា ចល័តគ្នាអីចឹង យាមថ្ងៃយាមខាងព្រៃដូងខាងកើត កន្លែងខាងកើតរទេះភ្លើង យើងនៅយាមដើរ យាមដឹងតែយាម ។

ដានី : អត់មានទៅណាទៀតនៅតែកន្លែងយាមទេ?

សន : បាទ!

ដានី : បើអត់យាម ពេលវេនយើងសំរាក?

សន : សំរាកដាំបាយ ដូរគ្នាដាំបាយធម្មតាអីចឹង ដាំបាយខ្លួនឯង ។

ដានី : អីចឹងកាលហ្នឹងយើងហូបបាយទេ?

សន : ហូបបបរដែរ បបររឹងៗ ។

ដានី : ម្ហូបអីបានយើងមានសំបូរទេ?

សន : ម្ហូបគេយកមកឲ្យ មួយអាទិត្យអីចឹងគេឲ្យសាច់ជ្រូកហូបម្តងអីចឹងទៅ ហើយរ៉ឺម៉កម៉ូតូគេដឹកឬស្សីក្រោល មិនដឹងដឹកមកពីណាពីណីខ្ញុំអត់ដឹងទេ យកមកដឹងតែធ្វើ ។

ដានី : គេឲ្យយើងប្រជុំអីដែរ ពេល?

សន : ប្រជុំកសាងគ្នាទៅ ។

ដានី : កសាងម៉េច?

សន : កសាងចង់និយាយរឿងអាវុធយើងកាន់១-២អីចឹង ដើរ១-២ កុំឲ្យធ្វេសប្រហែស មិត្តឯងរហ័ស គេចេះតែកសាង ។

ដានី ៖ វុធ ឈ្មោះ វុធ ហ្នឹងអ្នកប្រជុំ កសាង?

សន ៖ ដួនកាលគាត់អត់បានប្រជុំទេ គាត់ឲ្យតាមក្រុម តាមពួក ធ្វើការតាមក្រុម តាមពួកអីចឹង ប្រជុំពួក ។

ដានី ៖ មានដែលមកប្រជុំនៅកន្លែងមន្ទីរភូមិភាគ មន្ទីរតំបន់អីដែរ?

សន ៖ អត់ ។

ដានី ៖ កាលហ្នឹងពូស្គាល់គណៈតំបន់ គណៈភូមិភាគទេ?

សន ៖ គណៈតំបន់អត់ស្គាល់ទេ បើ តាម៉ុកៗ ខ្ញុំស្គាល់ប៉ុន្តែស្គាល់ក៏ភ្លេចដែរកាលហ្នឹងគាត់នៅតាកែវ

ដានី ៖ តាម៉ុក គាត់នៅតាកែវ?

សន ៖ បាទ!

ដានី ៖ ប៉ុន្តែគាត់មកនៅក្តាប់នៅភូមិភាគ នៅបាត់ដំបង នៅពាយ័ព្យហ្នឹងដែរ?

សន ៖ កាលហ្នឹងដូចជាគាត់ជាប់មកហ្នឹងដែរមិនដឹង ខ្ញុំអត់បានទាក់ទង បានកំលាំងបានអីយកមកហ្នឹង ខ្ញុំអត់សូវច្បាស់ដែរ ខ្ញុំនៅស្មើរៗខ្ញុំដំរាបប្រាប់ហើយ ខ្ញុំអត់សូវដឹងអីរឿងការងារ ។

ដានី ៖ កាលហ្នឹងនៅតូចៗ?

សន ៖ បាទ! តូច ឲ្យធ្វើអីដឹងតែធ្វើហ្នឹង ។

ដានី ៖ កាលហ្នឹងមកបានយូរដែរ បានឃួនចូល?

សន ៖ យូរដែរ បានវៀតណាមចូល កាលហ្នឹងមកនៅបានប្រហែល ដើរនៅនោះ២-៣ខែអីចឹង ។

ដានី ៖ ពូមកនៅយាមហ្នឹងរយៈពេលប៉ុន្មានហើយ? យាមក្មៀវចិនហ្នឹង ។

សន ៖ យូរដែរប្រហែលជាជាប់ជិតកន្លះឆ្នាំដែលហ្នឹង បានវៀតណាមចូលកាលហ្នឹងប្រហែលជា៤ខែ ជាង ៥ខែ ។

ដានី ៖ ដល់ហើយមានផ្លាស់ទៅណាទៀត?

សន ៖ អត់មានផ្លាស់ទៅណា រត់ រត់បែកគ្នា មិនដឹងអង្គភាពទៅណាមកណា រត់របៀត់របៀយមក រត់ តាមគេតាមឯង ។

ដានី ៖ កាលហ្នឹងអត់មានបានទៅផ្ទះវិញ?

សន ៖ អត់បានទៅផ្ទះវិញទេ រត់មកនៅរហូត នៅទល់សព្វថ្ងៃ ។

ដានី ៖ ដល់វៀតណាមចូលរត់តែម្តង?

សន ៖ រត់បណ្តោយ ។

ដានី ៖ រត់មកជាមួយអង្គភាពយ៉ាងម៉េចទៅ?

សន : ជាមួយអន្តភាពបាក់បែក អន្តភាពអស់ បាក់បែកមិនដឹងទៅណាមកណា បែកដូចកូនមាន់ចោលមេ មេចោលកូនអីចឹង ចេះតែរត់ទៅ ហើយបានគេមករៀបខ្ញុំនៅកងតាប៉ៃទល់សព្វថ្ងៃ ៧៩ដាច់បន្តិច មិនបាច់បញ្ចូលជាមួយកម្មករ ចេះតែនៅទៀត ។

ដានី : ជាមួយកងតាប៉ៃ?

សន : បាទ!

ដានី : កង៩០៥ហ្នឹង?

សន : ៩០៥ហ្នឹង ច្របាច់ចូលគ្នាជាមួយពួកកម្មករខ្លះអីចឹង ពួកកងចល័តខ្លះ ។

ដានី : គ្នាច្រើនទេកាលហ្នឹង?

សន : ច្រើន មកច្រើន កាលហ្នឹងរត់មកពេញតែព្រៃ មិនដឹងទៅណាណី ដាច់ទឹកដាច់ភក់ពេញណាពេញណី ។

ដានី : រត់ពីបាត់ដំបងមកដល់ហ្នឹង យូរទេបានមកដល់ហ្នឹង?

សន : យូរដែរ រត់នៅក្រាញៗ បងៗគាត់មកពីកោះកុង មកវៃគ្នា ទប់គ្នានៅមួយជួរយើងភ្នំសំពៅទ្រុងមាន់ កំពីងពួយ បឹងកន្សា ។

ដានី : កាលហ្នឹងពូធ្វើទាហាននៅ?

សន : កាលហ្នឹងវៃ ទ័ពវៃមែនទែន ចូលមកវៃតែម្តង ។

ដានី : កាលហ្នឹងពូនៅកងណា?

សន : នៅជាមួយបងៗដែលរត់មកពីខាងកោះកុង ។

ដានី : កោះកុង?

សន : បាទ! ខាងកោះកុង ខ្ញុំអត់សូវស្គាល់ដែរ គេឲ្យនៅហ្នឹងចេះតែវៃ រៀបបាយ ខ្ញុំនៅស្ទើរៗ មិនសូវបានវៃប៉ុន្មានទេ យកបាយឲ្យគេអីចឹង គេប្រើចេះតែទៅ ។

ដានី : ដល់ពេលចេញពីភ្នំសំពៅហ្នឹងមកណាទៀត?

សន : ចេញមក៧៩ មករត់ ៧៩រត់ចូលព្រៃ មកព្រៃធំមកអីហ្នឹង ព្រៃធំយើងហ្នឹងជិតភ្នំ១០៥ កំពីងពួយមកកាត់ព្រៃធំ យើងដៅស្នឹងនៅហ្នឹង ចេះតែនៅ អត់អីធ្វើចេះតែនៅហ្នឹងគេហ្នឹងឯង អត់ហ៊ានមកទេ បើគេថាទៅអត់បានទេ កាលហ្នឹងក្តាប់អត់បានដែរ ចេះតែមកតាមគេ ខ្ញុំអត់ហ៊ាន ។

ដានី : ដល់ពេលណាបានមកដល់ខាងយើង?

សន : មកនៅនេះ?

ដានី : បាទ!

សន : មកនេះឆ្នាំ ប្រហែល៨០-៨១-៨២ បានឈរជើងនៅនេះ ។

ដានី : អីចឹងចន្លោះ៧៩-៨០ យើងនៅតាមអ្នកណាខ្លះ?

សន : ៧៩ខ្ញុំនៅតាមកង តាមបង១ដែលមកពីកោះកុង ដល់ពេលមកនេះបានរៀបត្រឹមត្រូវ រៀប ៧៩មករៀបជាមួយកងតាប៉ែហ្នឹងនៅកណ្តាលទី រៀបកាលហ្នឹង ៧៩ដល់មក៨០មកអី បាន មកនៅឈរជើងតាមខត្តរ ។

ដានី : តាប៉ែ គាត់ធ្វើអីដឹបូង?

សន : ខ្ញុំក៏អត់ដឹងដែរ ខ្ញុំដឹងតែគាត់ពីដើមគាត់នៅពលវរៈសេនាធំ គាត់កងវរៈសេនាធំ៩០៥ ។

ដានី : គាត់ប្រធានបញ្ជាការ?

សន : បាទ! ពីដើមខ្ញុំអត់ដឹង គាត់នៅណាណី ដល់បែកបានខ្ញុំស្គាល់ ចូលត្រៀបបានខ្ញុំស្គាល់ ។

ដានី : កងពល?

សន : កងពល៦៤ ពីដើម ។

ដានី : កងពល៦៤?

សន : ២០៥ ។

ដានី : កងពល២០៥?

សន : បាទ! គេហៅ៦៤តែម្តង កង៦៤ ។

ដានី : ពីណាប្រធានកងពល?

សន : កន យើង ។

ដានី : តាកន នី កន?

សន : តាកន នី កន ។

ដានី : គាត់កងពល៦៤?

សន : គាត់ប្រធានកងពល ។

ដានី : ចុះបន្ទាប់ៗគាត់ពីណាខ្លះទៀត?

សន : ខ្ញុំអត់សូវស្គាល់ទេ ខ្ញុំស្គាល់ខ្ញុំធ្លាប់ឃើញមុខគាត់ គេឲ្យខ្ញុំទៅរៀននៅកន្លែងឡាន៨៩នឹងម្តង ដល់ពេលចឹងខ្ញុំបានស្គាល់គាត់ម្តងនឹង រៀននៅនឹង ស្គាល់គាត់ ។

ដានី : តាប៉ែ?

សន : ប៉ែ ស្គាល ប៉ែ នឹងគាត់កាន់វរៈសេនាធំហ្នឹងតែម្តង ក្នុង៣ឆ្នាំហ្នឹង ។

ដានី : កងពល៦៤ ទិសយើងពីត្រង់ណាទៅណា?

សន : ៦៤ ដូចពីជិតបឹងត្រកួនមកនេះ បឹងត្រកួនយើង ។

ដានី : បឹងត្រកួនខាង?

សន : ហៃទៅ ជិតកន្លែងខ្មែម ។

ដានី : ដល់ខ្មែមទៀត គ្រប់គ្រងនៅខ្មែមហ្នឹងដែរ?

សន : អត់ទេ កន្លែងខ្មែមហ្នឹងផ្សេង កងពលគេផ្សេង ។

ដានី : កងពលរបស់អ្នកណាគេ?

សន : ខាង បងគង់ មិនដឹងខាងអី បងគង់ ចៅហ្វាយស្រុករាល់ថ្ងៃ កាលមុនអ្នកណាធំដែលខ្ញុំចាំអត់សូវបានដែរ ប៉ុន្តែដោយឡែកពីគ្នា ដួនកាលខាងនោះចេះទំនាក់ទំនងគ្នា ចេះតែរកគ្នា ។

ដានី : សុខ គង់ គាត់ទៅខាងវរៈសេនាធំ ទៅខាងខ្មែម ខាងកំរៀង?

សន : បាទ!

ដានី : ពីនេះ តាប៉ៃ?

សន : តាប៉ៃ ។

ដានី : តាប៉ៃ នៅមុខព្រួញពីត្រឹមណាទៅណា? វរៈសេនាធំ?

សន : វរៈសេនាធំ ពីមុខព្រួញមួយជួរកាបីន កាលហ្នឹងវាកាន់មុខព្រួញបានតិចៗដែរកាលហ្នឹង បើកងពលបានឆ្ងាយ តំបន់កាន់បានឆ្ងាយ ។

ដានី : ចុះលោកពូនៅក្នុងវរៈសេនាធំ៩០៥ មាននៅកងអីផ្សេងទៀត?

សន : នៅកងវរៈសេនាតូច ។

ដានី : វរៈសេនាតូចអី?

សន : វរៈសេនាតូច៤០២ ។

ដានី : ៤០២?

សន : បាទ!

ដានី : មានតួនាទីអីដែរកាលហ្នឹង?

សន : ខ្ញុំគ្មានតួនាទីស្អីទេ ធម្មតាយុវជនរហូត កាលហ្នឹងចេះតែធ្វើ ។

ដានី : នៅជាមួយ កងទ័ពសុទ្ធសាធ អត់មាននៅជាមួយមេទេ?

សន : អត់ដែលបាននៅជាមួយមេៗទេ ។

ដានី : នៅកងប្រយុទ្ធតែម្តង?

សន : ប្រយុទ្ធរហូត ដឹង...គេប្រើដឹងតែទៅ ។

ដានី : យើងវ៉ៃម៉េចខ្លះទៅកាលហ្នឹង ត្រង់ណាមុខព្រួញវ៉ៃ?

សន : វ៉ៃឈ្លបវ៉ៃអី អត់មានវ៉ៃទ្រង់ទ្រាយធំ យូរៗវ៉ៃយុំអីចឹងម្តង យូរៗវ៉ៃធំម្តង រឿងវ៉ៃគ្នា ជួនកាលវ៉ៃមួយយប់៣ដង ឡើងវ៉ៃ១យប់ហ្នឹងឡើងវ៉ៃ៣ដង ..វ៉ៃឈ្លប វ៉ៃជាក្រុមតូច ។

ដានី : យួនមានដែលមកដល់ហ្នឹងទេ?

សន : ដល់តាំ ។

ដានី : យួនមកដល់ហ្នឹងដែរ?

សន : បាទ! យួនលើភ្នំព្រឹក្ស នៅហ្នឹង ។

ដានី : ដល់ពេលយើងទៅណាទៅ?

សន : កាលហ្នឹងភ្នំព្រឹក្ស កាលហ្នឹងនៅដីថៃ នៅសប់ពិលី នៅចេះតែឡើងមកវ៉ៃម្តងៗ ឡើងមកដី យើងវ៉ៃ ។

ដានី : ឆ្នាំណាដែលយួនចូលមកដល់ហ្នឹង?

សន : ៨២ កាលហ្នឹង៨២វ៉ៃខ្លាំងណាស់ គឺឡូ១៣នោះ ដាក់គ្នាមិនដែលបានដេក ...វ៉ៃ ។

ដានី : យើងមកវ៉ៃនេះវិញ?

សន : បាទ! នៅកប់ត្រង់សេ វ៉ៃធម្មតានៅតាមបណ្តោយព្រំដែនអីចឹង ។

ដានី : ដូចថាគ្រួសារ កូនចៅ ស្រីៗអី នៅក្នុងដីថៃ?

សន : បាទ! នៅដីថៃ ។

ដានី : ថៃគេឲ្យយើងនៅដែរ?

សន : ថៃកាលហ្នឹងគេថ្នាក់លើគេយកទៅទំនាក់ទំនងគ្នាមិនដឹង ខ្ញុំអត់ដឹងដែរ តែយើងគេចេះតែឲ្យនៅ បាន រឿងអីខ្ញុំអត់ដឹង តែខ្ញុំធ្លាប់នៅដីថៃខ្ញុំនៅទៅ នៅដូចថាវាសុខដែរ ចង់និយាយអីចឹង អត់បានមានបញ្ហាអី ។

ដានី : យួនវាមកនៅហ្នឹងយូរដែរ?

សន : នៅយូរ នៅឡើងតាំងពីវ៉ៃខ្លាំងខ្ញុំចាំបានឆ្នាំ៨២ មុន៨២ ៨១-៨២ វ៉ៃ ។

ដានី : ឆ្នាំណាទៅបានយើងវ៉ៃយកហ្នឹងវិញបាន យើងមកនៅនេះវិញ?

សន : កាលហ្នឹងខ្ញុំដាច់ជើងហើយ កាលហ្នឹងខ្ញុំដាច់ជើងតាំងពី៨៧មក ។

ដានី : ពូត្រូវអីដាច់ជើងហ្នឹង?

សន : ជាន់មីន ។

ដានី ៖ ដាន់មីន?

សន ៖ បាទ!

ដានី ៖ ដាន់នៅណាទៅ?

សន ៖ ដាន់នៅចង្អេរ ខ្ទីញ យើងនៅខាងកើតបាត់ដំបង កាលហ្នឹងខ្ញុំទៅនៅកើតបាត់ដំបង ។

ដានី ៖ ខាងកើតបាត់ដំបង?

សន ៖ បាទ! នៅបាទរនៅ អូ! បាទចោរ តាពូង ។

ដានី ៖ ខាងជិតពោធិ៍សាត់?

សន ៖ អត់ទេ ថ្មគោល ខាងកើតថ្មគោល អាព្រៃរនាម ព្រៃមួយដុំ ។

ដានី ៖ ដាន់មីនហ្នឹងមីនរបស់ខាងណា?

សន ៖ មីនហ្នឹងគេអ្នកដាក់ឲ្យខ្ញុំអ្នកឡើងទៅ ឡើងទៅហ្នឹងទៅពិនិត្យកន្លែងស្រូវ កន្លែងអង្ករកន្លែងថ្មគោល កន្លែងហ្នឹងមិនវៀតណាមវៃ កាលហ្នឹងវៃ ដល់វៃទៅរត់ចោលកន្លែងឃ្លាំងអង្ករ ឃ្លាំងស្រូវហ្នឹង ដល់អីចឹងវៀតណាមនៅកាន់កាប់ ខ្ញុំឡើងទៅ អ្នកដាក់គេ គេអត់ហ៊ានណា ខ្ញុំដើរមុន ដល់ដើរមុន ថាចាំ ។

ដានី ៖ មីនអ្នក?

សន ៖ មីនក្នាងង ។

ដានី ៖ មីនក្នាងង?

សន ៖ បាទ! ក្នាងងដាក់ហ្នឹងម៉ង ។

ដានី ៖ ដល់ពេលអីចឹងយើងអត់ដឹង?

សន ៖ អត់ដឹង ចុះអ្នកដឹងគេអត់នេះ គេថាចាំឲ្យជិតដល់ម៉េចៗចាំគេប្រាប់ ដំរាបថាខ្ញុំបើគេឲ្យទៅខ្ញុំនៅតែទៅបាន បាទ!អីចឹង ។

ដានី ៖ គេថាចាំជិតដល់មីន ចាំគេប្រាប់?

សន ៖ បាទ! ចាំគេប្រាប់ ដល់ពេលនេះហួសមីនមួយបាត់ហើយ ហួសមីនមួយហ្នឹងគេប្រាប់ថាហ៎ គ្រាន់តែស្រែកហ៎ ខ្ញុំបែរមកហ្នឹងតែម្ដង ម៉ាំង អាលាគខ្លួន ។

ដានី ៖ ឆ្នាំ៨៧?

សន ៖ ៨៧ ។

ដានី ៖ ដល់ពេលពូទៅដេកពេទ្យនៅណាទៅ?

សន ៖ ដេកពេទ្យកាលហ្នឹងគេសែងខ្ញុំមកព្រំដែនវិញ ។

ដានី ៖ មកព្រំដែន?

សន ៖ បាទ! សែនឆ្ងកាត់មកព្រែកឆ្មារនេះ យ៉ាប់ណាស់និយាយរឿងប្រវត្តិសែន ប្រវត្តិដើរហ្នឹង ...។

ដានី ៖ ពូការឆ្នាំណា?

សន ៖ ខ្ញុំការឆ្នាំ៩០ ។

ដានី ៖ កាលហ្នឹងពូពិការហើយ?

សន ៖ បាទ! ខ្ញុំពិការហើយ ។

ដានី ៖ ដល់ពេលយើងពិការហើយ យើងនៅធ្វើកងទ័ពទៀត ឬក៏ឈប់ហើយ?

សន ៖ នៅ នៅក្នុងអង្គភាព ។

ដានី ៖ អង្គភាពតែឡើងវ៉ៃទៀត ឬអត់ទេ?

សន ៖ អត់ទេ គេឲ្យនៅក្រៅ ឲ្យនៅជួយមើលមីងៗក្រោយអីចឹង គ្រួសារក្រោយៗ ។

ដានី ៖ ការឆ្នាំ៩០?

សន ៖ បាទ!

ដានី ៖ ប្រពន្ធពូគាត់ធ្វើអីដែរកាលនោះ?

សន ៖ ប្រពន្ធខ្ញុំដឹកជញ្ជូន ។

ដានី ៖ ដឹកជញ្ជូន?

សន ៖ បាទ!

ដានី ៖ គាត់រត់មកកាលឆ្នាំ៧៩ដែរ?

សន ៖ រត់មកជុំគ្នាដែរ នៅរោងចក្ររត់មក ស្គាល់គ្នាយកគ្នា មិនមែនយកអ្នកនេះ ចង់និយាយថា អ្នកជូរចត់ដែរ ។

ដានី ៖ ជូរចត់?

សន ៖ បាទ!

ដានី ៖ យើងពេញចិត្តគ្នាទៅវិញទៅមក យើងរៀបការខ្លួនឯង ឬខាងអង្គភាព ខាងមេៗគេចាត់ចែង ដូចថាឲ្យយើង?

សន ៖ ពេញចិត្ត កាលហ្នឹងពេញចិត្តទៅវិញទៅមកអីចឹង បានប្រាប់មេៗឲ្យគេនិយាយឲ្យ ឲ្យគេដណ្ដឹងឲ្យ ។

ដានី ៖ រៀបការនៅណា?

សន ៖ ការនៅ កាលហ្នឹងខ្ញុំនៅដីថៃ នៅសប់ពិលីយើង កន្លែងជិតផ្សារថៃរាល់ថ្ងៃ ។

ដានី ៖ ឆ្នាំ៩០ ?

សន ៖ បាទ! កាលហ្នឹងរៀប ស្នើរអន្តោភាព ស្នើរអន្តោ ។

ដានី ៖ ការតាមប្រពៃណីអី?

សន ៖ តាមប្រពៃណី ។

ដានី ៖ មានអាចារ្យ មានអី?

សន ៖ បាទ! មាន មានលោកមានអី កាលហ្នឹងខ្ញុំសុំគេ កាលហ្នឹងអីចឹងប្រពន្ធខ្ញុំការនៅជំរុំ ជំរុំយើងនេះជំរុំតាផុកនេះ ហ្នឹងគេមានបងមានប្អូន ។

ដានី ៖ បងប្អូនគាត់មកដល់ហ្នឹងដែរ?

សន ៖ អត់ទេ បងប្អូននៅជំរុំនោះទេ ប៉ុន្តែកាលហ្នឹងយើងចេញចូលបាន ដល់ពេលអីចឹងសុំគេទៅគេថាធ្វើម៉េចធ្វើទៅ ដោះស្រាយម៉េចកុំឲ្យទាក់ទងគេអីចឹង ដល់អីចឹងខ្ញុំក៏បានទៅការ អត់មានការនៅអន្តោភាពទេ ខ្ញុំសុំគេ គេថាការផាំអន្តោភាពរវល់មួយពីរ គេអត់ហ៊ានអនុញ្ញាតឲ្យខ្ញុំ ដល់អីចឹងខ្ញុំទៅការនោះក៏ថាបានដែរ តែមុននឹងទៅខ្ញុំជំរាបគេដែរ មេអត់ថាអី ខ្ញុំក៏ទៅការទៅអីហ្នឹង ខ្ញុំមកនៅអន្តោភាពវិញ ។

ដានី ៖ ការហើយបានមកនៅហ្នឹងវិញ ទាំងប្តីទាំងប្រពន្ធមកនៅអន្តោភាពវិញ?

សន ៖ ការហើយមកនៅហ្នឹងវិញ គ្រាន់តែទៅការទេ ការហើយមកវិញ ។

ដានី ៖ មកនៅអន្តោភាពវិញ ប៉ុន្តែពូនៅខាងក្រោយ?

សន ៖ បាទ! នៅក្រោយកាលហ្នឹង ។

ដានី ៖ អត់មាននៅមុខទេ?

សន ៖ អត់មាននៅមុខ ។

ដានី ៖ ខាងក្រោយយើងធ្វើអីខ្លះទៅ?

សន ៖ ក្រោយកាលជំនាន់ហ្នឹង យើងឲ្យដើរបិទចំរូង ឲ្យមើលតាមព្រំដែន យាមតាមព្រំដែន នៅប្រយ័ត្នតាមព្រំដែនអីចឹងដូចរាល់ថ្ងៃអីចឹង ឲ្យដាក់ចំរូង គេឲ្យបិទចំរូងយើងបិទចំរូង ។

ដានី ៖ ការហើយកាលហ្នឹងយើងអត់ទាន់បានចូលមកនៅនេះវិញទេ?

សន ៖ ការហើយខ្ញុំមកវិញហើយ ដូចរបៀបទៅការមកវិញ ។

ដានី ៖ តែយើងចូលមកនៅដីយើងវិញ ដូចមកនៅកន្លែងរាល់ថ្ងៃនេះ?

សន ៖ នៅដីយើងព្រំដែន នៅកន្លែងវរៈព្រំដែន ។

ដានី ៖ យួនចេញអស់?

សន ៖ កាលហ្នឹងយួនចេញអស់ ។

ដានី ៖ មានមីនច្រើនទេ?

សន ៖ មីននៅពេញតែព្រៃ មីនផ្លូវ៣៥កាលហ្នឹងនៅពេញ ព្រៃមិនទាន់កាប់ ។

ដានី ៖ ឥលូវអស់នៅ?

សន ៖ អស់ហើយCMAS គេរាវអស់ហើយ ។

ដានី ៖ តាមយើងនេះក៏អស់ដែរ?

សន ៖ រាវអស់ កាលមុនចូលអត់បានទេព្រៃនេះ មីនក្រាស់ ចំរូងដែកក៏ចំរូង មីនក៏មីន តាមក្បែរ ជើងភ្នំ តាមអូរ ។

ដានី ៖ ក្រោយមកពូមានបានឡើងឋានៈ មានតួនាទីអីដែរអត់?

សន ៖ អត់ ដូចខ្ញុំប្រាប់ ដែលបានធ្វើអីទេ ខ្ញុំរាល់ថ្ងៃខ្ញុំហូបលុយខែ កន្លែងសង្គមកិច្ចរាល់ថ្ងៃក៏ដាក់ គេនេះខ្ញុំ តែខ្ញុំដាក់ធម្មតា ។

ដានី ៖ នៅតែយុទ្ធជន?

សន ៖ បាទ! យុទ្ធជនធម្មតា ហូបលុយខែ ហូបលុយយុទ្ធជន ។

ដានី ៖ បាន១ខែប៉ុន្មានដែរ?

សន ៖ ខ្ញុំបាន១២ម៉ឺនជាង ។

ដានី ៖ ១២ម៉ឺន មួយខែ?

សន ៖ បាទ! សង្គមកិច្ចគេអាហ្នឹងលុយ ។

ដានី ៖ លុយគោលនយោបាយ?

សន ៖ បាទ! គោលនយោបាយ ។

ដានី ៖ បើកទៀងទាត់ដែរ?

សន ៖ បានទៀងទាត់ដែរ ជួនកាលហួសខែតិចតួច ។

ដានី ៖ ប៉ុន្តែគេអត់ដែលបំបាត់ខែយើងទេ?

សន ៖ អត់ទេ នៅតែបើកប៉ុណ្ណឹង ។

ដានី ៖ បានប្រាក់ខែ មានរបបបន្ថែមលើប្រាក់ខែទេ?

សន ៖ អត់ដែលបានអីទេ ។

ដានី ៖ បានតែ១២ហ្នឹង?

សន ៖ បាទ!

ដានី ៖ បើកនៅណាទៅ?

សន ៖ បើកនៅកន្លែងសាលាស្រុក កន្លែងការិយាល័យ ។

ដានី ៖ កន្លែងសង្គមកិច្ច?

សន ៖ សង្គមកិច្ច បាទ ។

ដានី ៖ ហ្នឹងយើងលែងទៅអង្គភាព ទៅអីទៀត យើងនៅតែ?

សន ៖ ខ្ញុំធម្មតា នៅតាមភូមិ-ឃុំនេះ ។

ដានី ៖ យើងធ្វើការធម្មតាទៅ?

សន ៖ សព្វថ្ងៃខ្ញុំចុះតាមភូមិ-ឃុំអីចឹង តែខ្ញុំបើកលុយភូមិបាលកន្លែងការិយាល័យផ្សេង ។

ដានី ៖ យើងធ្វើការ យើងធ្វើការងារ ដូចពួរៀបរាប់មុិញ ធ្វើប៉ះកង់ ធ្វើចម្ការ ធ្វើអីធម្មតា អត់ចាំបាច់ទៅអង្គភាពទេ?

សន ៖ បាទ! អត់ទេ គេកាត់ចេញពីអង្គភាពហើយ ។

ដានី ៖ គេកាត់ចេញហើយ?

សន ៖ បាទ! កាត់ចេញហើយ មកនៅសង្គមកិច្ចគេគ្រប់គ្រងវិញ ហើយខ្ញុំរាល់ថ្ងៃនៅតាមភូមិ-ឃុំ ។

ដានី ៖ ហើយពូកាលពីយើងធ្វើសមាហរណកម្មនៅនេះ ធ្វើសមាហរណកម្មឆ្នាំណា?

សន ៖ សមាហរណកម្ម ខ្ញុំដូចភ្លេចឆ្នាំដែរ ដូចជា៩៤-៩៥-៩៦ ។ យាយកាលហ្នឹងសមាហរណកម្ម ឆ្នាំប៉ុន្មាន កាលហ្នឹង?

ដានី ៖ ៩៦?

សន ៖ ដូច៩៦ ខ្ទង់៩៦ ។

ដានី ៖ សមាហរណកម្មតំនាល ៗ ខាងបប៉ៃលិន ខាងម៉ាឡៃអីដូចគ្នា?

សន ៖ បាទ!រហូត បឹងត្រកួនហើយ បានបប៉ៃលិនហើយ បានយើងនេះ កាលមុន ។

ដានី ៖ ម៉េចទៅកាលយើងដំណើរការសមាហរណកម្ម?

សន ៖ សមាហរណកម្ម ខ្ញុំអត់សូវដឹងដែរ ខាងបប៉ៃលិនគេចុះចូលរដ្ឋាភិបាល ខាងបឹងត្រកួនក៏អីចឹងដែរ ដល់អីចឹងខាងនេះ តាមខ្ញុំភ្លាប់បានតាមខ្ញុំដឹង ដល់អីចឹងរុលតាមគ្នា អត់មានអីទូងទាំងអត់មានបាញ់ប្រោកអីទេ អត់មាន ។

ដានី ៖ មេ ៗ អីម៉េច លឺថាមេប្រទូសសារ៉ាយគ្នាអីម៉េច?

សន ៖ ប្រទូសសារ៉ាយដែរ តែកូនៗអត់ធ្វើ ។

ដានី ៖ កូនៗអត់ធ្វើ?

សន ៖ បាទ! កូនអត់ធ្វើ ដល់អីចឹងវាចប់ទៅ វាសុខសប្បាយអីចឹងទៅ ។

ដានី ៖ តា សុន សេន គាត់មកដែរ?

សន ៖ សុន សេន មកប្រជុំនៅសាលា៦៤ កន្លែងសាលា២៥០ កន្លែង៦៤ កន្លែងកងពលនៅហ្នឹង មកកាលហ្នឹងប្រជុំនៅម៉ោ មេភូមិម៉ោ កាលនឹងមានមេភូមិមេអីហោទៅ ។

ដានី ៖ ចុះគាត់ប្រជុំអី គេនៅនឹងចូលចិត្តគាត់អត់ តាសុន សេន?

សន ៖ ដូចអត់សូវមានអ្នកណាចូលចិត្ត ។

ដានី ៖ អត់សូវចូលចិត្តគាត់?

សន ៖ បាទ!

ដានី ៖ គាត់ម៉េច?

សន ៖ ទឹងត្រង់ថាអារឿងអី១-២ ដកអីទ្រព្យសម្បត្តិ ដូចរទេះគោ ដូចអី១-២ លិចកើត ។

ដានី ៖ ម៉េចបានគាត់ដក?

សន ៖ មិនដឹងគោលការណ៍គេធ្វើយ៉ាងម៉េច ខ្ញុំអត់ដឹងដែលកាលហ្នឹង ។

ដានី ៖ ដកឆ្នាំណាកាលហ្នឹង?

សន ៖ ខ្ញុំវាអត់សូវចាំឆ្នាំហ្នឹងទៀត ។

ដានី ៖ មុនសមាហរណកម្ម?

សន ៖ ធ្វើមុនសមាហរណកម្ម ដល់ក្រោយមកប្រហែលកន្លះខែ-១ខែ បានប្រទូសសារ៉ាយអីចឹង ។

ដានី ៖ គាត់ឲ្យដកទ្រព្យសម្បត្តិ ដូចជា រទេះគោ របស់របរ?

សន ៖ និយាយរួមថាកម្មសិទ្ធ ។

ដានី ៖ គាត់ឲ្យយកទៅដាក់រួម?

សន ៖ បាទ! ដកសូម្បីតែម៉ាស៊ីនកាប់ឈើតូចៗ ដកយកទៅអស់ អត់មានឲ្យ ។

ដានី ៖ គេអត់ពេញចិត្តទេត្រង់ហ្នឹង?

សន ៖ បាទ! ដល់អីចឹងគេអ្នករកស៊ីខ្លះគេអត់ពេញចិត្ត ។

ដានី ៖ ចុះខាង ដូចថាមេៗ ខាងវរៈសេនាធំ ដូចខាងកងពលគេពេញចិត្តទេ?

សន ៖ ខាងកងពលខាងអី ធម្មតា ដោយកន្លែង ដូចភូមិចក្រីវិញ គេមានសមត្ថភាព គេមានរកស៊ីបាន ជួនកាលគេស្រលាញ់មេគេអីចឹងទៅ បើមេខ្លះអត់ឲ្យរក ។

ដានី ៖ បានន័យថាគេពេញចិត្តជាមួយ សុន សេន ដែលឬគេមិនពេញចិត្តទេ ខាងមេៗទាហាន?

សន ៖ មិន ដូចអត់ពេញចិត្ត ភាគច្រើនអត់ អត់ពេញចិត្តច្រើន ។

ដានី ៖ កាលហ្នឹងពូកាលហ្នឹងគេដកអីខ្លះដែរ?

សន ៖ ខ្ញុំអត់មានអីឲ្យគេដកទេកាលហ្នឹង ។

ដានី ៖ អត់មានទេ?

សន ៖ បាទ! ធ្វើចម្ការ ចេះតែលបកាប់ គេមិនកាប់អីចឹងខ្ញុំទៅកាប់ចង់ដួលខ្ញុំរត់មកផ្ទះ ខ្យល់មកដួលទៅ ដល់ថ្ងៃក្រោយកាប់ទៀតទៅ មានថវិការទៅដាំស្រូវទទួលទានទៅ អត់មានអីហ្នឹងគេ ។

ដានី ៖ ពូដល់ពេលគេសមាហរណកម្មហើយ នៅហ្នឹងរហូត អត់មានផ្លាស់ប្តូរអីទេ?

សន ៖ អត់ដែលទៅណា មកណាទេ ។

ដានី ៖ ពូចាប់ដីបានច្រើនដែរ?

សន ៖ ចាប់ដីបានប៉ុន្មាន ។

ដានី ៖ គេចែករបបដីដែរ?

សន ៖ ដីគេចែក ឬផ្ទះខ្ញុំតាមអត្តភាពគេចែក ។

ដានី ៖ បានប៉ុន្មានដែរ?

សន ៖ ២៣ កន្លែងខ្លះ២០ កន្លែងខ្លះបាន២៣ ។

ដានី ៖ បណ្តោយ?

សន ៖ បណ្តោយទៅក្រោយឆ្ងាយដែរហ្នឹង ចង់១០០ជាង ។

ដានី ៖ បណ្តោយយើងចងបានប៉ុន្មាន ក៏បានដែរ?

សន ៖ បាទ! បណ្តោយយើងមានលទ្ធភាពកាប់ ចេះតែកាប់ទៅកាលហ្នឹងគេអត់ថាអីទេ ។

ដានី ៖ ចុះដីចម្ការ ដីស្រែ ហ្នឹងគេចែក ឬយើងកាប់ខ្លួនឯង?

សន ៖ កាប់ខ្លួនឯង អត់មានអ្នកចែកទេ តស៊ូធ្វើតែម្តង ។

ដានី ៖ ឆ្ងាយពីផ្ទះ ឬជិត?

សន ៖ ខ្ញុំនេះក្រោយ ខ្ញុំមិនដែលទៅណារួច លើកតែក្រោយនឹងគេ កាលហ្នឹងជិទាន់ហ្នឹងបើសិនមានមេគេឆ្លាត គេដឹកនាំទៅកាប់ណាណើ កាប់ចម្ការនេះអីចឹង មេនេះអត់សូវគិត កូនអត់ដែរ ។

ដានី ៖ កាលហ្នឹងមេពីណាគេ?

សន ៖ មេនេះ ពូសុន មេៗ លឿក គាត់ខូចអស់ហើយ លឿក គាត់ស្លាប់អស់ហើយ ។

ដានី ៖ អនុសេនាធំ ឬក៏វរៈ?

សន ៖ វរៈសេនាធំ កាលហ្នឹងត្រៀម វរៈសេនាធំ វរៈសេនាតូចពីដើម ។

ដានី ៖ វរៈសេនាតូច?

សន ៖ បាទ!

ដានី ៖ តាប៉ៃ គាត់ឡើងទៅណាវិញទៅ?

សន ៖ តាប៉ៃ ដូចធ្វើអីកាលហ្នឹង ខ្ញុំដូចដាច់វយៈដែរកាលហ្នឹង ខ្ញុំនៅតែក្រោយខ្ញុំអត់សូវដឹងដែរ ខ្ញុំអត់សូវបាននៅតាមកងនៅអីគេ ។

ដានី ៖ ពូដីបានប៉ុន្មានម៉ែត្រ បានប៉ុន្មានរៃដីចម្ការ?

សន ៖ ដីចម្ការខ្ញុំកាប់បានប្រហែលជា២៨-២៩រ៉ៃ ជិត៣០រ៉ៃ ។

ដានី ៖ ជិត៣០រ៉ៃដែរ?

សន ៖ បាទ!

ដានី ៖ ហ្នឹងយើងកាប់ខ្លួនឯង តាមកំលាំងយើងកាប់បាន?

សន ៖ កំលាំងខ្លួនឯង ចេះតែកាប់ទៅ ព្រលឹមឡើងហូប វេចបាយទៅកាប់ គេកាប់បានច្រើនដែរៗ គេអ្នកនេះ ខ្ញុំកាប់ក្បែរៗនេះ ។

ដានី ៖ អ្នកផ្សេងៗគេកាប់បានច្រើនជាងពូ ឬក៏បានប្រហែលគ្នា?

សន ៖ ដីខ្ញុំកុំអីអត់បានជិតហ្នឹងទៀត ដីហ្នឹងមីន គេអត់សូវកាប់ទេ គេអត់ហ៊ានទេ ដល់អីចឹងខ្ញុំចេះតែ ភាវ ។

ដានី ៖ ភាវខ្លួនឯង?

សន ៖ បាទ! មួយថ្ងៃកាប់បានបន្តិច ។

ដានី ៖ ពូចេះភាវមីនដែរ?

សន ៖ ចេះ ។

ដានី ៖ ចេះភាវខ្លួនឯង?

សន ៖ ភាវអាមីនខ្សែមើលឃើញ មីននៅនឹងដីចេះតែចូកអីចឹងទៅ ធ្វើម៉េចបើអត់ទៅហើយចេះទ្រាំ ចូក បើប៉ះអីក៏បាន បើមិនប៉ះអីក៏បានរស់ដល់សព្វថ្ងៃទៅ ។

ដានី ៖ សំណាងដែលអត់មានប៉ះអី?

សន ៖ បាទ!

ដានី ៖ កាប់តែម្នាក់ឯងទេ ប្រពន្ធអត់មានជួយកាប់ទេ?

សន ៖ ប្រពន្ធអត់ហ៊ានដែលឲ្យទៅទេ ខ្លាចក្រែងលោបប៉ះមីន ប្រពន្ធទៅទាល់តែកន្លែងណាវាល បាន ខ្ញុំហៅទៅ ១-២ថ្ងៃ ជួយរើ ព្រៃខ្ញុំអត់ឲ្យទៅទេ ។

ដានី ៖ ឥលូវយើងលែងកាប់អីៗបានទៀតហើយ?

សន ៖ លែងកាប់បានហើយ ។

ដានី ៖ របស់យើងមានប៉ុន្មានប៉ុណ្ណឹងហើយ?

សន ៖ បាទ!

ដានី ៖ ចម្ការពូធ្វើបានផលបានអីគ្រប់គ្រាន់ដែរអត់?

សន ៖ ពិបាកណាស់ ទប់ទល់រហូត ។

ដានី ៖ ឆ្នាំទៅលើថាដំឡូងបានថ្លៃបានអីគ្រាន់បើ?

សន ៖ ខ្ញុំអត់ធ្វើផង ទើបតែធ្វើឆ្នាំនេះ ឆ្នាំទៅខ្ញុំដាំស្រូវ ។

ដានី ៖ ស្រូវបានគ្រប់គ្រាន់ផ្គត់ផ្គង់ជីវភាព?

សន ៖ ស្រូវបាន អស់ទៀតហើយនេះស្រូវ ។

ដានី ៖ ទើបនេះតាំម៉េច?

សន ៖ ចុះកូនចៅវាច្រើន ។

ដានី ៖ បានប៉ុន្មានឆ្នាំទៅ?

សន ៖ បាន៨-៩បាវ ។

ដានី ៖ បានតិចដែរ?

សន ៖ តិច តែដីក្រោយខ្ញុំជួលគេ ក្រៅពីហ្នឹងខ្ញុំអត់លទ្ធភាពធ្វើ ចង់និយាយថាអត់មានធនធានធ្វើ វល់តែខ្ចីរបស់គេមកអស់ដីហ្នឹងទៀតម៉េចទៅ ។

ដានី ៖ អត់ហ៊ានប្រថុយ?

សន ៖ អត់ហ៊ាន សុខចិត្តតិចច្រើនអីធ្វើ យកលុយទិញជាអង្ករ ទិញជាស្បៀងអីហូបវិញ ។

ដានី ៖ អត់លក់អត់ដូរទេ ដីហ្នឹង?

សន ៖ អត់លក់ទេ ។

ដានី ៖ ដីនេះមានតម្លៃដែរ?

សន ៖ មាន ថោក ។

ដានី ៖ ១រ៉ៃបានប៉ុន្មាន?

សន ៖ ១រៃ ១ម៉ឺនដាង ១ម៉ឺន១ពាន់លុយបាត ថោកដី បើធ្វើចម្ការលំបាកដែរ រឿងទឹកភ្លៀង លំបាកដែររឿងទឹកភ្លៀង បើធ្វើត្រូវៗ បើមិនត្រូវលក់ដីសងគេ យកលុយឲ្យគេ ។

ដានី ៖ ព្រោះយើងពឹងពាក់លើមេឃ?

សន ៖ បាទ! អីចឹងខ្ញុំអត់ហ៊ាន ធ្វើតែតិចៗ ក្រោយផ្ទះទេ៣-៤រៃក្រោយទេ ។

ដានី ៖ ពូដែលទៅលេងស្រុកទេ?

សន ៖ ខ្ញុំទៅបាន២-៣ដងដែរ ។

ដានី ៖ ២-៣ដង ។ ទៅដំបូងទៅឆ្នាំណា?

សន ៖ ទៅដំបូង កាលសមាហរណកម្មហើយទៅតែម្ដង ។

ដានី ៖ សមាហរណកម្មហើយទៅ?

សន ៖ ទៅ គេចេះតែថាខ្លាចនេះ ខ្លាចនោះ ខ្ញុំថាខ្ញុំដើរលែងខ្លាចហើយប៉ុណ្ណេះៗហើយ នឹកឃើញថា យើងទៅតាមផ្លូវ ។

ដានី ៖ បែកប៉ុន្មានឆ្នាំបានទៅផ្ទះ?

សន ៖ បែកយូរ តាំងពី៧៦-៧៧ពីស្រុកមក ដល់យើងមកសមាហរណកម្ម៩៥-៩៦នេះ ។

ដានី ៖ ៩៦?

សន ៖ ៩៦ ដល់អីចឹងវាយូរឆ្នាំដែរ ។

ដានី ៖ អត់ដែលជួបគាត់ អត់ដែលលឺដំណឹងអីសោះ?

សន ៖ អត់ អត់ដែលសោះ ទៅតែម្ដង ។

ដានី ៖ ទៅដំបូងម៉េចដែរ ដល់ពេលឪពុកម្ដាយឃើញដំបូង បងប្អូនបង្កើត?

សន ៖ ទៅដំបូងគេចេះតែមើល អ្នកជិតខាងឯងទៅជើង២ មកវិញឯងជើងមួយ ខ្ញុំថាធ្វើម៉េចបាន មកឃើញមុខអ្នកស្រុកហ្នឹង បានអរគុណណាស់ ។

ដានី ៖ កាលហ្នឹងឪពុកពូកាលពូទៅ គាត់ស្លាប់ហើយ?

សន ៖ ខូចអស់ទាំងអស់ ។

ដានី ៖ អស់ហើយទាំងឪពុកទាំងម្ដាយ នៅសល់តែបងប្អូន?

សន ៖ បាទ! សល់តែបងប្អូន បាត់ឪពុកម្ដាយអស់ ។

ដានី ៖ គាត់នៅចាំ នៅចំណាំអីដែរ?

សន ៖ បាទ! នៅចាំទៅឃើញស្គាល់តែម្ដង ។

ដានី ៖ ពូទៅដល់នៅចាំផ្ទះ នៅចាំស្រុកភូមិដែរ ឬសួរគេសួរឯងដែរ?

សន ៖ ទៅតាមផ្លូវសួរគេ ។

ដានី ៖ យើងទៅរកភូមិខ្លួនឯងអត់ឃើញដែរ?

សន ៖ អត់សួរគេ គេប្រាប់ទៅនេះទៅនោះ ទៅជួបបងប្អូនបានស្គាល់ ។

ដានី ៖ ទៅលេងបានប៉ុន្មានថ្ងៃដែរ?

សន ៖ ទៅលេងបានប្រហែលជាជាង១អាទិត្យដែរ ។

ដានី ៖ ទៅម្នាក់ឯងឬទៅទាំងគ្រួសារ?

សន ៖ ទៅម្នាក់ឯងដំបូង ទៅតែម្នាក់ឯងដំបូង ។

ដានី ៖ ទៅដំបូងទៅម្នាក់ឯង?

សន ៖ បាទ!

ដានី ៖ បងប្អូនពូមានដែលមកលេងដល់នេះទេ?

សន ៖ មកដែរ ឥលូវឆ្នាំនេះបែបខ្សោយថវិការបានមិនដែលឃើញមក យ៉ាប់ដែរឥលូវ ។

ដានី ៖ គាត់ខាងនោះគាត់រាងអត់សូវធូរធារដែរ?

សន ៖ អត់ដែរ ។

ដានី ៖ ពូក្រោយទៀតទៅលេងទៀត?

សន ៖ បាទ! ទៅ ។

ដានី ៖ ប្រពន្ធពូ កូនៗមានដែលធ្លាប់ទៅលេងស្រុកកំណើតពូទេ?

សន ៖ ទៅគ៉ា ។

ដានី ៖ ទៅដែរ?

សន ៖ បាទ! មានរវល់ក្នុងស្រុកក្នុងអី កូនក្មួយ រៀបការជូនទៅចេះតែទៅ ។

ដានី ៖ ពូអត់ចង់ទៅនៅស្រុកវិញទេ?

សន ៖ ទៅនៅស្រុកដីងមានអី អត់មានអី នឹកស្រុកកំណើតចេះតែនឹកហើយ ប៉ុន្តែទៅមានណា បើយើងខាងដើមអត់មានអីទេ ចេញមកពោរគេចេញមកមួយខ្លួន ហើយមានអ្នកណាដីដូចស្រុកកំណើតនេះវិញបាត់ហើយ ។

ដានី ៖ ឥលូវស្រុកកំណើតដូចនៅនេះវិញ?

សន ៖ បាទ! នៅនេះវិញហើយ ។

ដានី ៖ ដូចញាតិមិត្តជិតខាងអីដូចបើសិនជាយើងនៅជាមួយគ្នាយូរហើយ វាស្និតស្នាល?

សន ៖ អត់អីទេ ។

ដានី ៖	នៅស្រុកកំណើតដូចមិត្តភ័ក្ត្រពូកាលនៅក្មេង ទៅវិញស្គាល់គ្នាដែរ?

សន ៖	អត់អីដែរ ទៅគេចេះ ។

ដានី ៖	ស្គាល់គ្នា ឬភ្លេចគ្នាអស់ហើយ?

សន ៖	អត់អីដែរ គេចេះតែសួរសុខទុក្ខលិចកើតអីចឹងដែរ ។

ដានី ៖	នៅសួរសុខទុក្ខធម្មតា?

សន ៖	បាទ! ឯងនៅនោះម៉េច ឯងរកស៊ីម៉េចអីម៉េចអីចឹង យើងថាមានមករកស៊ី មករកស៊ីធម្មតា ចម្ការធ្វើចម្ការ យើងនៅនេះស្រែធ្វើស្រែ ។

ដានី ៖	ពូគិតថានៅនេះស្រួលជាងឬយ៉ាងម៉េច?

សន ៖	នៅនេះស្រួលជាងព្រោះនៅនេះមានដី មានអីចឹង ខ្ញុំរកបានតិចតួចអីធ្វើផ្ទះធ្វើសំបែងឲ្យកូនឲ្យចៅ ។

ដានី ៖	ពូដូចថាតាំងពី ដូចថាបើចិត្តពូវិញ តាំងពីមុនសមាហរណកម្ម ហើយក្រោយសមាហរណកម្មមកដល់ឥលូវនេះម៉េចដែរ មួយណាស្រួលជាង?

សន ៖	ពីមុនយ៉ាប់ យ៉ាប់ត្រង់ណាមិនសូវដែលបានសំរាកដែលបានអី រវល់រហូតកង់និយាយទៅថ្ងៃណាក៏ថ្ងៃដើររុក ប្រើចេះតែទៅ មិនសូវបានសំរាកមិនសូវបានអី ។

ដានី ៖	ចុះក្រោយសមាហរណកម្មហើយ?

សន ៖	ហើយអត់អីស្រួលខ្ញុំ ស្រួលអត់មានលំបាកអីទេ ។

ដានី ៖	អត់មានលំបាកអីទេ?

សន ៖	បាទ!

ដានី ៖	គិតថាយើងរស់នៅស្រួលជាង?

សន ៖	បាទ!

ដានី ៖	ក្រោយពីសមាហរណកម្មហើយ?

សន ៖	ក្រោយសមាហរណកម្មមករស់នៅស្រួល អត់ដែលលំបាកអី១-២ទេ អត់មានការអីលំបាកលំបិន១-២ទេ បានអីបានត្រង់ថាការងាររកផ្គត់ផ្គង់គ្រួសារ លំបាកត្រង់ថាដូចថាការងាររកអីលិចកើតចិញ្ចឹមគ្រួសារចិញ្ចឹមអីមក មានគ្រួសារចេះតែនឹកគិតកូន នឹកគិតប្រពន្ធអីចឹង ចេះតែគិតកន្លែងហ្នឹង ។

ដានី ៖	តាមខ្ញុំជួបពូមីងមួយចំនួន គាត់នៅតំបន់ផ្សេងៗដូចជានៅប៉ៃលិន នៅម៉ាឡៃអី អ្នកខ្លះ១ចំនួនតូច គាត់ថាកាលមុនសមាហរណកម្មយើងមានរបប យើងមានអី យើងមិនសូវខ្វល់ថា

តើត្រូវរកស៊ីចិញ្ចឹមជីវិត ចិញ្ចឹមគ្រួសារ ដឹងតែថាយើងទៅវ៉ៃៗទៅ ទៅធ្វើការបិទចំរូងអីចឹងទៅ ដល់ខែយើងបើករបប បើកអង្ករ បើកម្ហូបដូចជាត្រីខ ត្រីអី ដល់ក្រោយសមាហរណកម្មហើយយើងត្រូវរកស៊ីខ្លួនឯង ផ្គត់ផ្គង់ខ្លួនឯងបើយើងរកមិនបានគឺយើងអត់ អាហ្នឹងម៉េចដែរបើតាមចិត្តពូ ពូគិតថា?

សន : អាហ្នឹងមួយបែបម្នាក់ដែរ
កាលហ្នឹងយើងហូបបាយគេយើងធ្វើការងារឲ្យគេខ្ញុំនិយាយចេះវិញ
ដល់ក្រោយមកទៀតយើងត្រូវការហូបខ្លួនឯង ត្រូវការរកទទួលទានខ្លួនឯង កាលមុនឧទាហរណ៍ថាសែងគូទឡាន គេយកអង្ករមកបើកឲ្យយើង អាហ្នឹងសំរាប់ទស្សនៈគេមើលឃើញម៉េចខ្ញុំមិនដឹង តែខ្ញុំថារាល់ថ្ងៃស្រួលជាង អានេះស្រួលជាង។

ដានី : យើងរកខ្លួនឯង បានខ្លួនឯង?

សន : បាទ! អានេះស្រួលជាង ទោះបីខ្ញុំពិការប៉ុណ្ណេះ យ៉ាងណាក៏ខ្ញុំរកវិធី រកនេះរកនោះ ឲ្យតែដូចសព្វថ្ងៃ វាមិនភ័យ វាមិនរយើងរយូងគ្រាប់រំសេវពេញៗខ្លួន ដើរទល់ៗភ្លឺ បាទ!ចេះ។

ដានី : កាលហ្នឹងយ៉ាប់?

សន : បាទ! យ៉ាប់។

ដានី : ឥលូវយើងអាចថាយើងរកបានច្រើន យើងសល់?

សន : មិនបានអីចេះតែឈ្នួសឈ្នល់រកទៅ យ៉ាងណាក៏ខ្ញុំចាត់ទុកថាមិនលំបាកដល់ប៉ុណ្ណេះ ចង់និយាយថារាល់ថ្ងៃមានស្ថេរភាព ចង់និយាយថាមានការរកស៊ី។

ដានី : វាមិនសង្គ្រាម មិនច្បាំងគ្នា?

សន : ហ្នឹងហើយ អត់មានទីងទាំង អត់មានផ្ទុះ។

ដានី : យើងចង់ទៅណាក៏បានដែរ?

សន : បាទ! ចង់និយាយកន្លែងហ្នឹង បើចង់ទៅណាយើងរកលុយកាក់អីបានអីចឹងយើងទៅ។

ដានី : កូនចៅក៏បានរៀនសូត្រដែរ?

សន : បាទ! កាលមុនគ្មានទេ កាលមុនអត់មានស្ថេរភាពអីទេ ចង់និយាយថាការរកស៊ីក៏អត់មានអីក៏អត់។

ដានី : មួយទៀតសព្វថ្ងៃគេមាន ខាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ គេបង្កើតជាតុលាការដែលគេកាត់ទោសរាល់ថ្ងៃ ដូចជាកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ហើយកាំង ហ្កេកអ៊ាវ ហៅឌុច ដែលជាអតីតប្រធានមន្ទីរសន្តិសុខស២១ ហៅគុកទួលស្លែងហ្នឹង

ត្រូវបានតុលាការកាត់ទោស គេកាត់ទោសគាត់រួចហើយ ខាងមុខទៀតគេនឹងកាត់ទោសមេដឹកនាំជាន់ខ្ពស់ដូចជា នួន ជា, ខៀវ សំផន, អៀង សារី និងប្រពន្ធគាត់ កាត់ទោសនៅខាង មុខនេះ ។ ចុះបើតាមពូផ្ទាល់ ការគិតរបស់ពូ ពូយល់ឃើញថាការបង្កើតតុលាការ ការកាត់ ទោសត្រឹមត្រូវដែរ ឬមិនត្រឹមត្រូវទេ បើតាមចិត្តពូ?

សន : កន្លែងហ្នឹងខ្ញុំពិបាកនិយាយ ពិបាកនិយាយដែរកន្លែងហ្នឹង ខ្ញុំអត់សូវដឹងរឿង អត់សូវដឹងហេតុ ដូចខ្ញុំជំរាបពីខាងដើម ថាខ្ញុំពីដើមគេប្រើខ្ញុំទៅណា ខ្ញុំទៅហ្នឹងហើយ រឿងអស់ហ្នឹងខ្ញុំអត់សូវ ចង់និយាយថា ។

ដានី : ចង់ថាក្នុងចិត្ត យើងនិយាយពីការមិនមែនវិភាគតាមនេះទេ ការយល់ឃើញរបស់ពូវិញ តើពូធ្លាប់រស់នៅជាមួយពួកគាត់ ឬយ៉ាងម៉េច ឥលូវគេកាត់ទោសពួកគាត់ ហើយចិត្តពួកគាត់ថាកាត់ទោសហ្នឹងមិនត្រឹមត្រូវទេ មូលហេតុចេះ ឬកាត់ទោសហ្នឹងត្រឹមត្រូវមូលហេតុចេះ?

សន : អាហ្នឹងពិបាកដូចខ្ញុំប្រាប់បង ខ្ញុំគំនិតរបស់ខ្ញុំវិញ ច្បាប់គេធ្វើម៉េច ធ្វើគេកាត់ដឹកនាំពីដើមម៉េចចេះចុះអីចឹង បើច្បាប់វិនិច្ឆ័យថាឃើញគាត់ខុស ខ្ញុំក៏មិនដឹងនិយាយថាយ៉ាងម៉េចដែរ បើតាមគំនិតខ្ញុំមិនបាច់ឲ្យគេធ្វើអីណាណីទេ គាត់ចាស់ៗអស់ហើយ ។

ដានី : ខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំពូទៀតហើយ ពូមានអីចង់បន្ថែមអ្វីដែលខ្ញុំអត់ទាន់សួរនាំពូ?

សន : អត់មានអីបន្ថែម ។

ដានី : បាទ!

សន : ទ្រឹស្តីអត់សូវបានទេ ។

ដានី : អីចឹងខ្ញុំអរគុណច្រើនចំណាយពេលសំណេះសំណាលជាមួយខ្ញុំ ។

សន : បាទ!

**«ចប់»**